ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

TRUST REGULATOR

និយ័តករបរធនបាលកិច្ច

លេខ: ០០១/២២ ន.ប.ធ./ស.ជ.ណ.

ថ្ងៃ ពុធ ១៥ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២

## សេចក្តីជូនដំណឹង

## ស្តីពីការអនុវត្តប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២

## ស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល និងបុគ្គលពាក់ព័ន្ធនៅក្នុងវិស័យបរធនបាលកិច្ចទាំងអស់ មេត្តាជ្រាបថា÷ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានដាក់ឱ្យអនុវត្តជាផ្លូវការនូវប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី **"វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"** ចាប់ពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ នេះតទៅ។ អនុលោមតាមប្រកាសនេះ បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ដែលបានបង្កើតបរធនបាលកិច្ច ហើយមិនទាន់បានចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ច ដោយបំពេញបែបបទ និងនីតិវិធីតាមការកំណត់របស់ **ន.ប.ធ.** ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ជាកំហិត គិតចាប់ពីប្រកាសនេះចូលជាធរមាន។

ជាមួយគ្នានេះ បរធនបាលដែលគ្រប់គ្រង ចាត់ចែង និងថែរក្សាសុវត្ថិភាពទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានចុះបញ្ជីមុនប្រកាសនេះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ដោយបំពេញតាមបែបបទ និងនីតិវិធីនិយ័តកម្មតាមការកំណត់របស់ **ន.ប.ធ.** ដោយអនុលោមតាមប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ជាកំហិត គិតចាប់ពីប្រកាសនេះចូលជាធរមាន។

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម បុគ្គលរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ត្រូវស្នើសុំចុះបញ្ជីនៅ **ន.ប.ធ.** ដោយអនុលោមតាមប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ជាកំហិត គិតចាប់ពីប្រកាសនេះចូលជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល និងបុគ្គលពាក់ព័ន្ធនៅក្នុងវិស័យបរធនបាលកិច្ចទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករបរធនបាលកិច្ច**

ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

សូមទាញយកប្រកាសនេះតាមរយៈ QR Code ខាងក្រោម÷

អាសយដ្ឋាន : អគារ ១៦៨F (ជាន់ទី៨) សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh